# ៤.  ទត្តមានបរិស្ថាន

## ៤-១  លក្ខណៈជីវរូបសាស្ត្រ

### ៤-១-១ អាកាសធាតុ

#### ៤-១-១-១ សីតុណ្ហភាព

៩២. អាកាសធាតុនៅក្នុងប្រទេសជាទូទៅមានលក្ខណៈជាអាកាសធាតុបែបសំណើមត្រូពិក ឬមូសុងត្រូពិក (Humid-Tropical or Tropical Monsoon) ជាអាកាសធាតុក្តៅ-សើម ដែលមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ។ សីតុណ្ហភាពមានលក្ខណៈខុសគ្នាតិចតួចទៅតាមអន្តរតំបន់ជាងកត្តាបរិស្ថាន និងថាវរូបបន្តផ្សេងៗទៀត ដែលអាចមានឥទ្ធិពល។ ភាពខុសគ្នាខ្លាំងរបស់សីតុណ្ហភាព អាចបណ្តាលមកពីទីតាំងភូមិសាស្ត្រពោលគឺរយៈកំពស់ ដែលមានការប្រែប្រួលក្នុងចន្លោះពី 0-៨0ម ប្រៀបធៀបនឹងនីវ៉ូសមុទ្រ (**ឧបសម្ព័ន្ធ ៤-២:ផែនទី១ ផែនទីរយៈកំពស់ដី**) និងគំរបពពកដែលមានការផ្លាស់ប្តូរតាមរដូវកាល។ តាមប្រភពទិន្នន័យពីសីតុណ្ហភាពខេត្តកំពង់ធំ នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ[១] (ឆ្នាំ ២000-២00៩)បង្ហាញថា ខេត្តកំពង់ធំ មានសីតុណ្ហភាពអតិបរិមាគិតជាមធ្យមនៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ៣១.៣-៣៣.៥ អង្សាសេ។ ចំណែកសីតុណ្ហភាពអប្បបរមាគិតជាមធ្យមនៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ២១.៥-៣១.៣ អង្សាសេ (**ឧបសម្ព័ន ៤-១: តារាង ១,២**)។

#### ៤-១-១-២ កំពស់ទឹកភ្លៀង

៩៣. ជាទូទៅអាកាសធាតុរបស់ប្រទេសកម្ពុជា មានលក្ខណៈខុសគ្នា និងមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ។ ជាក់ស្តែងខ្យល់ស្ងួតបានបក់ពីភូមិភាគឦសានទៅភូមិភាគនិរតីនៃប្រទេស ដោយមាននាំទាំងទឹកភ្លៀងតិចតួចមកជាមួយផង យើងហៅរដូវនេះថាជារដូវប្រាំង ហើយរដូវនេះមានរយៈពេល៦ខែ គឺចាប់ផ្តើមពីខែវិច្ឆិកា ដល់ខែមេសា។ ចំណែកឯរដូវវស្សាបានចាប់ផ្តើមពីខែឧសភា ដល់ខែតុលា ក្នុងពេលដែលខ្យល់មូសុងបានបក់ពីភូមិភាគនិរតីឆ្ពោះទៅខ្ពង់រាបឦសាននៃប្រទេស ដែលបាននាំមកនូវភ្លៀងដ៏ខ្លាំងដល់តំបន់ទំនាបកណ្តាល ហើយរបបទឹកភ្លៀងនេះបានជះឥទ្ធិពលដល់ការរីកលូតលាស់ និងដំណុះរបស់រុក្ខជាតិ។ តាមការអធិប្បាយរបស់លោក D.Crocker ១៩៦២ និង Anonymous, ១៩៩៧,៩៨ តំបន់ដែលទទួលភាពរាំងស្ងួតជាងគេនៅក្នុងប្រទេសកម្ពុជាគឺអាងទន្លេសាបដូចជា : តំបន់ដីទំនាបភាគខាងជើង និងខាងត្បូងនៃជួរភ្នំដងរែក ដែលភាពរាំងស្ងួតបានអូសបន្លាយរយៈពេលរហូតដល់ទៅ 0៦ខែ និងទទួលនូវរបបទឹកភ្លៀងប្រចាំឆ្នាំមានកំរិតទាបជាង ១.៤៧៧ម.ម។ តាមការសិក្សាទៅលើកំពស់ទឹកភ្លៀងដែលបានកត់ត្រានៅឯស្ថានីយ៍ ខេត្តកំពង់ធំ

[១] ប្រភព: ស្ថានីយ៍ឧតុនិយម ខេត្ត កំពង់ធំ

Draft

នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយ (២០០០-២០០៩) បានឱ្យដឹងថាមធ្យមភាគកំពស់ទឹកភ្លៀងប្រចាំឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ១២០៦,១-១៩៤៥,៤ ម.ម (**ឧបសម្ព័ន្ធ៤-១ តារាង៣**) ។

## ៤-១-២ ភូគព្ភសាស្ត្រ និងឋានលេខា

៩៤. ដីនេះស្ថិតនៅតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជា ស្ថិតនៅប៉ែកខាងជើងទន្លេសាប ហើយបន្តរហូតដល់ភ្នំដងរែក ទទួលរបបទឹកភ្លៀងជាមធ្យម១៤០០-២០០០ម.ម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំស្ថិតក្នុងចន្លោះ ២៦,៥៤-២៦,៨៨ដឺក្រេសែលស៊ុស ដែលរដូវប្រាំងមានរយៈពេលច្រើនជាង៤ខែ (DANIDA, 2003)។ នៅរដូវវស្សាតំបន់នេះចាប់ផ្តើមមានភ្លៀងធ្លាក់នៅដើមខែឧសភា ឋានលេខារបស់ដីសម្បទាននេះមានលក្ខណៈរាបស្មើ។ ជាទូទៅដីស្រទាប់លើ (០-២០ស.ម) មានពណ៌លឿង ភាគច្រើនសម្បូរណ៍តូចៗ មានអង្កត់ផ្ចិតពី០,០២-១,០ស.ម មានពណ៌លឿងហើយផុយស្រួយ ជាដីដែលខ្សត់សារជាតិខនិក ដោយសារតែករិតជំរាបខ្ពស់។ នៅក្នុងជម្រៅពី ២០-៤០ស.ម ដីមានពណ៌លឿងហើយម៉ត់ មានលាយល្បាយខ្សាច់មានគ្រាប់គ្រើមបង្គួរ កន្លែងខ្លះមានដុំថ្មធំៗ (លឿង-ប្រផេះ តែផុយស្រួយ) ដែលមានទំហំពី ១,០-៤,០ស.ម។ នៅក្នុងជម្រៅពី ៤០-៦០ស.ម មានវាយនភាពជាដីឥដ្ឋល្បាយខ្សាច់ មានពណ៌លឿងចាស់ កន្លែងខ្លះក្រហម-ក្រម៉ៅ។ ដីនៅតាមជំរាលអូរ និងពោះអូរ មានវាយនភាពជាដីល្បាយខ្សាច់ពណ៌ប្រផេះក្រម៉ៅ សម្បូរណ៍កំទិចកំណរសារធាតុសរីរាង្គ-ពពួកមមោគ (ស្លឹកនិងកំទិចឈើ) ដែលកើតឡើងពីការពុកផុយនៃរុក្ខជាតិជាយូរឆ្នាំ។ នៅរដូវប្រាំងស្ថានភាពដីតំបន់នេះ មានភាពងាយស្រួលក្នុងការធ្វើដំណើរ និងការដឹកជញ្ជូនផល-អនុផលព្រៃឈើ ។

៩៥. ដីជាតិអាចកំណត់ដោយសិលាមេដែលមានស្ថិតនៅស្រទាប់ក្រោម លក្ខណៈគីមីរបស់ដីតែងតែបញ្ជាក់អំពីករិតនិងលំនាំនៃការបំបែកធាតុរបស់សិលាមេក្នុងយុគសម័យភូគព្ភសាស្ត្រ និងលក្ខណៈរបស់ថ្មដែលជាសិលាមេ ។ ដំណើរប្រព្រឹត្តទៅនៃបាតុភូតភូគព្ភសាស្ត្រនេះបានទទួលរងនូវឥទ្ធិពលអាកាសធាតុ ពេលវេលា ឋានលេខា និងដំណើរប្រព្រឹត្តទៅតាមលក្ខណៈជីវសាស្ត្រធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្វ និងបាក់តេរី។ កត្តាទាំងអស់នេះអាចបញ្ជាក់ដោយផ្ទាល់ និងដោយប្រយោលអំពីដីដែលមានលក្ខណៈជាអាស៊ីតពណ៌ រចនាសម្ព័ន្ធ ដីជាតិ លទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក។ យោងតាមផែនទីភូគព្ភសាស្ត្រ បង្ហាញថាដីរបស់ក្រុមហ៊ុន **ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ** មានសិលាមេ៣ប្រភេទ ដូចមាន បង្ហាញជូននៅក្នុងតារាង៤-១ ខាងក្រោម ហើយប្រភេទសិលាមេទាំង០៣គឺៈ (១) Floodplains (១២ហិកតា ) ស្មើនឹង ០,១៦ភាគរយ (២) Lake bed deposits (៧ហិកតា) ស្មើនឹង០,០៩ ភាគរយ (៣) Peneplain laterite deposits (៧២៧០ហិកតា) ស្មើនឹង៩៩,៧៥ ភាគរយ នៃផ្ទៃដីសរុប (ឧបសម្ព័ន្ធ៤-២ៈ **ផែនទី២.៣ ផែនទីភូគព្ភសាស្ត្រ និងឋានលេខា**) ។

Draft

តារាង ៤-១: ចំណាត់ថ្នាក់ប្រភេទសីលាមេនៅក្នុងតំបន់សម្បទាន

| ប្រភេទសីលាមេនៅក្នុងតំបន់សម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| តំបន់សម្បទានទាំងមូល | | |
| **Floodplains** | ១២ | ០,១៦ |
| **Lake bed depsits** | ៧ | ០,០៩ |
| **Peneplain laterite deposits** | ៧២៧០ | ៩៩,៧៥ |
| **សរុបរួម** | **៧២៨៩** | ១០០ |

## ៤-១-៣ ចំណាត់ថ្នាក់ប្រភេទដីនៅក្នុងតំបន់ដីវិនិយោគ

**៩៦.** យោងតាមលក្ខណៈដីនិងឋានលេខាដីរបស់ក្រុមហ៊ុន **ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ** មានដី២ប្រភេទ គឺ: (១) Plinthite Podzols មានទំហំ ១៤៣ ហិកតា ឬស្មើនឹង ១,៩៦ភាគរយ នៃផ្ទៃដីសរុប នៅជ្រុងខាងត្បូងសណ្តូកពីទិសខាងលិចទៅកើត (២) Red-yellow podzols មានទំហំ ៧១៤៦ហិកតា ឬស្មើនឹង ៩៨,០៤ ភាគរយ ស្ថិតនៅគ្របដណ្តប់ក្នុងតំបន់ដីសម្បទាន ទាំងមូល( **ឧបសម្ព័ន្ធ៤-២ ផែនទី៤ ផែនទីចំណាត់ថ្នាក់ប្រភេទដី**) ។

**៩៧.** យោងតាមរបាយការណ៍របស់លោក D. Crocker ក្នុងឆ្នាំ ១៩៦២-៦៣ នៅក្នុងរយៈពេលនៃការធ្វើអង្កេតលើលក្ខណៈអេកូឡូស៊ីដែលបានប្រព្រឹត្តទៅពេលថ្មីៗនេះ ភាគច្រើននៃប្រភេទរបស់ដីនៅក្នុងតំបន់ដីសម្បទានបានរក្សាទុកនូវសភាពដើមដោយគ្មានអ្វីប្រែប្រួលគួរឱ្យកត់សំគាល់ឡើយ បើប្រៀបធៀបជាមួយនឹងរបាយការណ៍របស់លោក D.Crocker លើកលែងតែការផ្លាស់ប្តូរមួយផ្នែកតូចប៉ុណ្ណោះដែលកើតមានជាពិសេសចំពោះដីល្បាប់ ។ ភាពប្រែប្រួលនេះអាចធ្វើការបកស្រាយបានដោយយោងទៅលើមូលហេតុនៃទឹកជំនន់ទៅតាមរដូវនៅក្នុងតំបន់ទំនាបរបស់ដីសម្បទាន ។ យោងទៅលើលក្ខណៈដើម និងលក្ខណៈនៃឋានលេខា យើងអាចបែងចែកប្រភេទដីដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម :

តារាង ៤-២ : ចំណាត់ថ្នាក់ប្រភេទដីនៅក្នុងតំបន់សម្បទាន

| ប្រភេទដីនៅក្នុងដីសម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| តំបន់សម្បទានទាំងមូល | | |
| Plinthite Podzols | ១៤៣ | ១,៩៦ |
| Red-yellow podzols | ៧១៤៦ | ៩៨,០៤ |
| **សរុបរួម** | **៧២៨៩** | ១០០ |

៩៧. តាមការធ្វើចំណាត់ថ្នាក់ដីរបស់ក្រសួងកសិកម្ម ប្រភេទដី Plinthite Podzols មានសក្តានុពលទាបសម្រាប់ការធ្វើកសិកម្ម ជាពិសេសចំពោះដំណាំរូមផ្សំ។ ដោយចំពោះ Red-Yellow Podzols វិញ ក៏ជាដីដែលមានវាយនភាពអាយទទួលរងការជ្រាបខ្ពស់ ដូច្នេះការប្រែក្លាយដីព្រៃប្រភេទនេះសម្រាប់ដាំដំណាំរូមផ្សំមិនមានអំណោយផលល្អទេ ព្រោះប្រឈមមុខនឹងការផ្តល់ជីបន្ថែមច្រើន។ (**ឧបសម្ព័ន្ធ៤-៣ :តារាងបែងចែក**ចំណាត់ថ្នាក់ប្រភេទដីរបស់ក្រសួងកសិកម្ម ) ។

### ៤-១-៤ ចំណាត់ថ្នាក់ជីជាតិដី

**៩៨.** យោងតាមចំណាត់ប្រភេទគុណភាពជីជាតិរបស់ដី នៅក្នុងតំបន់សម្បទានទាំងមូលមាន១ប្រភេទ (តារាង ៤-៣) គឺមានជីជាតិទាបមានទំហំ ៧២៨៩ហិកតា ឬស្មើនឹង ១០០ភាគរយ លាតសន្ធឹងពេញផ្ទៃដីសម្បទានទាំងមូល (**ឧបសម្ព័ន្ធ៤-២ ផែនទី ៩ ផែនទីជីជាតិដី**) ។

**តារាង ៤-៣ : ចំណាត់ថ្នាក់ជីជាតិដីនៅក្នុងតំបន់សម្បទាន**

| ចំណាត់ថ្នាក់ជីជាតិដីនៅក្នុងតំបន់សម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| **តំបន់សម្បទានទាំងមូល** | | |
| Low Productivity Soil | ៧២៨៩ | ១០០ |
| **សរុបរួម** | **៧២៨៩** | **១០០** |

### ៤-១-៥ ចំណាត់ថ្នាក់ទីជំរាល

**៩៩.** យោងតាមការអង្កេតលើចំណាត់ថ្នាក់ទីជំរាល (Slope Classification) បានលេខារបស់ដីសម្បទាននេះមានលក្ខណៈមិនរាបស្មើ និងមានចំណាត់ថ្នាក់ទីជំរាលប្រាំគឺ:

**ចំណាត់ថ្នាក់ទី១:** ដីតំបន់នេះមានចំណាត់ថ្នាក់ទីជំរាលកំរិត ០-២ដឺក្រេ ចំនួន ៧០៧៤ ហិកតា ស្មើនឹង ៩៧.០៥ ភាគរយ នៃផ្ទៃដីសរុប និងជាសណ្ឋានដីដែលមានលក្ខណៈរាបស្មើ។ ផ្អែកលើទស្សនៈ នៃការអភិរក្សទឹក និងដី តំបន់នេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ អាចប្រើប្រាស់សម្រាប់ដំណាំស្រូវ ដំណាំកសិកម្ម និងព្រៃឈើ ។ ជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ។

**ចំណាត់ថ្នាក់ទី២:** ដីតំបន់នេះមានចំណាត់ថ្នាក់ទីជំរាលកំរិត ២-៥ ដឺក្រេ ចំនួន ២១២ ហិកតា ស្មើនឹង ២.៩២៣ ភាគរយនៃផ្ទៃដីសរុប។ ដីតំបន់នេះមានលក្ខណៈស្ទើររាបស្មើ មិនមានតម្រូវការនៃការអភិរក្សទឹកនិងដីទេ ហើយផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះការប្រើប្រាស់ ដីមានលក្ខណៈទូលំទូលាយ អាចប្រើប្រាស់សម្រាប់កសិកម្ម និងព្រៃឈើ ។

**ចំណាត់ថ្នាក់ទី៣:** ដីតំបន់នេះមានចំណាត់ថ្នាក់ទីជំរាលកំរិតខ្ពស់ជាង៥ចំនួន២ហិកតា ស្មើនឹង ០.០២៧ ភាគរយនៃផ្ទៃដីសរុប។ ដីតំបន់នេះមានលក្ខណៈចោតបន្តិចម្តងៗឡើងទៅចំណោតខ្លាំង សណ្ឋានដីនេះមានលក្ខណៈច្រោះទាបជាងចំណាត់ថ្នាក់២ខាងលើ ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដី នៅតំបន់ទីជំរាល

ប្រភេទនេះការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ហើយការប្រើប្រាស់ដីតំបន់នេះ អាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម ប្រសិនបើអនុវត្តវិធានការអភិរក្សបានត្រឹមត្រូវ។ **(ឧបសម្ព័ន្ធ៤-២ ផែនទី ៦ ផែនទីចំណាត់ថ្នាក់ទីជំរាល)**

**តារាង ៤-៤ : ចំណាត់ថ្នាក់ ទីជំរាលដីនៅក្នុងតំបន់សម្បទាន**

| ចំណាត់ថ្នាក់ទីជំរាលដីនៅក្នុងតំបន់សម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| **តំបន់សម្បទានទាំងមូល** | | |
| 0 - ២$^0$ | ៧០៧៤ | ៩៧,០៥ |
| 0២ – 0៥$^0$ | ២១២ | ២,៩២៣ |
| >0៥ | ២ | 0,0២៧ |
| **សរុបរួម** | **៧២៨៩** | ១០០ |

### ៤-១-៦ ទឹកស្រទាប់លើ និងគុណភាពទឹក

១០០. ទឹកស្រទាប់លើៈ នៅតំបន់ដីសម្បទាននេះមិនសំបូរប្រភពទឹកស្រទាប់លើទេ។ តាមរយៈផែនទីប្រើប្រាស់ដី និងគំរបព្រៃបង្ហាញថា មានតែអូរតូចៗពីរប៉ុណ្ណោះ គឺអូរដូងត្រាច និងកោសលង់ (តាមអ្នកស្រុករស់នៅក្នុងឃុំសាគ្រាមជើង ហៅថាអូរពលង់)។ ក្រៅពីអូរទាំងពីរនេះចេញ នៅសង្កេតឃើញមានត្រពាំងតូចៗ ចំនួន0៥ តែត្រពាំងនេះភាពច្រើនរីងនៅក្នុងចុងរដូវប្រាំង។

១០១. ប្រភពដែលអាចបង្កនៃភាពក្រខ្វក់ដល់ទឹកៈ បច្ចុប្បន្នមិនមានការបំពុលទឹកអ្វីគួរអោយចាប់អារម្មណ៍នៅក្នុងតំបន់នោះទេ តែនៅថ្ងៃអនាគតប្រភពដែលអាចបង្កឱ្យមានភាពក្រខ្វក់ដល់ទឹកអាចកើតមានឡើងបានសកម្មភាពឈូសឆាយរានដីចំនួន ៧២៨៩ហិកតា ដើម្បីដាំដំណាំកៅស៊ូ នៅក្នុងករណីដែលប្រតិបត្តិការដាំដុះមិនបានអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថានបានត្រឹមត្រូវ។

១០២. **ការយកសំណាកទឹក និងការវិភាគៈ** ក្រុមការងារបានយកសំណាកទឹកអូរ0១កន្លែង កាលពីថ្ងៃទី 0២ ខែ មិថុនា ឆ្នាំ ២០១០ នៅត្រង់ចំណុចនិយាមកា (471760-1461469) ដើម្បីធ្វើការវិភាគអំពីលក្ខណៈរូប និងលក្ខណៈគីមី។ សំណាកនេះត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានដើម្បីធ្វើការវិភាគ។

១០៣. តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បង្ហាញថា **(១) លក្ខណៈរូប** - នៅក្នុងចំណោមថាវរូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅនេះ មានខ្ពស់ជាងកំរិតស្តង់ដាររបស់ទឹកដែលត្រូវបាន អនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងឧស្សាហកម្ម និងអង្គការសុខភាពពិភពលោក ពោលគឺ ៣០/0 ចំពោះ Total Coliform និង ១៤៦/0 ចំពោះ Total Bacteria និង **(២) លក្ខណៈគីមី** - នៅក្នុងចំណោមថាវរូបទាំង២0មានវត្តមានថាវរូបចំនួន0៤

ប្រភេទនេះការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ហើយការប្រើប្រាស់ដីតំបន់នេះ អាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម ប្រសិនបើអនុវត្តវិធានការអភិរក្សបានត្រឹមត្រូវ ។ (**ឧបសម្ព័ន្ធ៤-២ ផែនទី ៦ ផែនទីចំណោតថ្នាក់ទីជំរាល**)

**តារាង ៤-៤ : ចំណោតថ្នាក់ ទីជំរាលដីនៅក្នុងតំបន់សម្បទាន**

| ចំណោតថ្នាក់ទីជំរាលដីនៅក្នុងតំបន់សម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| **តំបន់សម្បទានទាំងមូល** | | |
| ០ - ២ ⁰ | ៧០៧៤ | ៩៧,០៥ |
| ០២ – ០៥ ⁰ | ២១២ | ២,៩២៣ |
| >០៥ | ២ | ០,០២៧ |
| **សរុបរួម** | **៧២៨៩** | ១០០ |

## ៤-១-៦ ទឹកស្រទាប់លើ និងគុណភាពទឹក

**១០០.** ទឹកស្រទាប់លើៈ នៅតំបន់ដីសម្បទាននេះមិនសំបូរប្រភពទឹកស្រទាប់លើទេ ។ តាមរយៈផែនទីប្រើប្រាស់ដី និងគំរបព្រៃបង្ហាញថា មានតែអូរតូច១ពីរប៉ុណ្ណោះ គឺអូរដូងត្រាច និងកោសលង់ (តាមអ្នកស្រុករស់នៅក្នុងឃុំសាគ្រាមជើង ហៅថាអូរពលង់) ។ ក្រៅពីអូរទាំងពីរនេះចេញ នៅសង្កេតឃើញមានត្រពាំងតូច១ ចំនួន០៥ តែត្រពាំងនេះភាពច្រើនរីងនៅក្នុងចុងរដូវប្រាំង ។

**១០១.** ប្រភពដែលអាចបង្កនៃភាពក្រខ្វក់ដល់ទឹកៈ បច្ចុប្បន្នមិនមានការបំពុលទឹកអ្វីគួរអោយចាប់អារម្មណ៍នៅក្នុងតំបន់នោះទេ តែនៅថ្ងៃអនាគតប្រភពដែលអាចបង្កឱ្យមានភាពក្រខ្វក់ដល់ទឹកអាចកើតមានឡើងបានសកម្មភាពឈូសឆាយរានដីចំនួន ៧២៨៩ហិកតា ដើម្បីដាំដំណាំកៅស៊ូ នៅក្នុងករណីដែលប្រតិបត្តិការដាំដុះមិនបានអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថានបានត្រឹមត្រូវ ។

**១០២. ការយកសំណាកទឹក និងការវិភាគៈ** ក្រុមការងារបានយកសំណាកទឹកអូរ០១កន្លែង កាលពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ នៅត្រង់ចំណុចនិយាមកា (471760-1461469) ដើម្បីធ្វើការវិភាគអំពីលក្ខណៈរូប និងលក្ខណៈគីមី ។ សំណាកនេះត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានដើម្បីធ្វើការវិភាគ ។

**១០៣.** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បង្ហាញថា (១) **លក្ខណៈរូប** - នៅក្នុងចំណោមថារ៉ូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅនេះ មានខ្ពស់ជាងកំរិតស្តង់ដាររបស់ទឹកដែលត្រូវបាន អនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងឧស្សាហកម្ម និងអង្គការសុខភាពពិភពលោក ពោលគឺ ៣០/០ ចំពោះ Total Coliform និង ១៤៦/០ ចំពោះ Total Bacteria និង (២) **លក្ខណៈគីមី** - នៅក្នុងចំណោមថារ៉ូបទាំង២០មានវត្តមានថារ៉ូបចំនួន០៤

ដែលជា Trace Metals (Nickel, Cobalt, Cadmium and Mercury) ដែលក្នុងករណីធម្មតាធាតុរូបទាំងនេះ មិនមាននៅក្នុងទឹកបរិភោគទេ។ ចំណែកឯ ធាតុរូបចំនួន១៦ ផ្សេងទៀតមិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៤-៤ : តារាងទី១លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន លេខ ៣៨ ពស.វទ**) ។

## ៤-២ ធនធានអេកូឡូស៊ី

### ៤-២-១ សហគមន៍សារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់ដី

#### ៤-២-១-១ សហគមន៍សារព័ន្ធរុក្ខជាតិ

១០៤. កំណើតដើមនៃប្រភេទព្រៃទាំងនៅក្នុងតំបន់សម្បទាននេះ គឺអាស្រ័យទៅនឹងអាកាសធាតុរបស់តំបន់ លក្ខណៈភូមិសាស្ត្រ សណ្ឋានដី និងសមាសភាពនៃប្រភេទឈើ ហើយប្រភេទព្រៃសំខាន់ៗ ទាំងនេះបានកើតឡើង ដោយសារអនុប្រភេទជាច្រើនទៀត។ ឯកសារយោងដែលបានប្រើជាមូលដ្ឋាននៅក្នុងរយៈពេលនៃការសិក្សា និងអង្កេតក្នុងតំបន់នេះ គឺរូបភាពផ្កាយរណបឆ្នាំ ១៩៩២-១៩៩៣, ១៩៩៧ របស់ UNDP GIS Dataset និងឆ្នាំ ២០០២ និង២០០៦ រដ្ឋបាលព្រៃឈើ (**ឧបសម្ព័ន្ធ៤-២ : ផែនទី ៧ ដល់១០ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) ។ នៅក្នុងរយៈពេលនៃការវាយតំលៃអំពីអេកូឡូស៊ី និងពាណិជ្ជកម្មរបស់ព្រៃ បានបញ្ជាក់ថា ស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់នេះត្រូវទទួលរងការរំខានធ្ងន់ធ្ងរ។ ឈើដែលមានតម្លៃពាណិជ្ជកម្ម ត្រូវបានដកហូតស្ទើរតែទាំងស្រុងហើយ។ ឧទាហរណ៍ជាក់ស្តែង បច្ចុប្បន្ននេះប្រជាពលរដ្ឋនៅក្នុងតំបន់កំពុងតែប្រមូលផលឈើផ្សៀកប្រភេទឈើលេខ-២ ដែលការប្រើប្រាស់នេះអាចបញ្ជាក់អំពីការធ្លាក់ចុះដ៏ធ្ងន់ធ្ងររបស់ឈើពាណិជ្ជកម្មនៅក្នុងតំបន់នោះ។ ចំពោះប្រភេទឈើលេខ-៣ និងឈើក្រៅលំដាប់ថ្នាក់ មាននៅសេសសល់បង្គួរ តែក៏ពុំមានអង្កត់ផ្ចិតធំដែរ។ ការសិក្សាអំពីការប្រែប្រួលស្ថានភាពសារពើរុក្ខជាតិក្នុងតំបន់សម្បទាននេះ ក្នុងចន្លោះឆ្នាំ ១៩៩២-២០០៦ បង្ហាញថា:

- **ឆ្នាំ១៩៩២-១៩៩៣:** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិពីរប្រភេទគឺ: ព្រៃស្រោង និងដីកសិកម្ម។

- **ឆ្នាំ១៩៩៦-១៩៩៧ :** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិពីរប្រភេទគឺ: ព្រៃស្រោង ដីកសិកម្ម និងផ្ទៃទឹក។

- **ឆ្នាំ២០០២:** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបីប្រភេទ: ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងដីគ្មានព្រៃ។

- **ឆ្នាំ២០០៦:** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិពីរប្រភេទគឺ: ព្រៃស្រោង និងដីគ្មានព្រៃ។

Draft

### ៤-២-២ ស្ថានភាព និងការប្រែប្រួលរបស់គំរបព្រៃ

១០៥. តាមរយៈការវិភាគ អំពីការប្រែប្រួលអំពីស្ថានភាពរបស់គំរបព្រៃក្នុងតំបន់ដែនសម្បទានទាំងមូល នៅក្នុងរយៈពេល១៤ឆ្នាំ(ឧបសម្ពន្ធ៤-២:ផែនទី-៦-១០)ចុងក្រោយដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់ UNDP GIS Dataset, 1992-93, 1997. FA GIS Dataset ២០០២ និង ២០០៦ បានបង្ហាញអោយដឹងថា ស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃមានការប្រែប្រួលគួរអោយចាប់អារម្មណ៍។ ដំណើរការបំរែបំរួលនេះមានបង្ហាញជូននៅក្នុងតារាង ៤-៥ ខាងក្រោម :

**តារាង ៤-៥: ការបង្ហាញអំពីដំណើរប្រែប្រួលស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃរយៈពេល១៤ឆ្នាំ**

| ប្រភេទព្រៃ | ១៩៩២-៩៣ | ១៩៩៧ | ២០០២ | ២០០៦ |
|---|---|---|---|---|
| ព្រៃស្រោង | ៧២៥៣ | ៧២៨៦ | ៧១៧១ | ៧០៥៦ |
| ព្រៃពាក់កណ្តាលស្រោង | | | ៣៤ | |
| ដីកសិកម្ម | ៣៦ | ៣ | | |
| ដីគ្មានព្រៃ | | | ៨៤ | ២៣៣ |

### ៤-២-៣ ប្រព័ន្ធមជ្ឈដ្ឋានហ៊្សែនរបស់តំបន់ទំនាបកណ្តាល

១០៦. ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CAOUC CO., LTD. មានប្រព័ន្ធមជ្ឈដ្ឋានហ៊្សែនស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល ដែលក្នុងនោះរាប់បញ្ចូលទាំងតំបន់ផលិតកម្មកៅស៊ូសំខាន់ៗ ហើយបង្កើតបានជាប្រព័ន្ធមជ្ឈដ្ឋានហ៊្សែនរបស់តំបន់ទំនាបកណ្តាលធំជាងគេ(១៨ភាគរយ)។ តំបន់ទំនាបនេះគឺអាងស្តុកទឹកសំខាន់មុនហូរចាក់ចូលទៅក្នុងទន្លេសាប និងទន្លេមេគង្គ។ តំបន់នេះផ្នែកខាងត្បូងបញ្ចប់នឹងតំបន់ដីក្រហម ខាងជើងជាប់នឹងភ្នំដងរែក ខាងលិចជាប់នឹងតំបន់ទំនាបខាងជើង និងខាងកើតជាប់នឹងតំបន់ទំនាបទន្លេមេគង្គផ្នែកខាងកើត។ តំបន់នេះមានលក្ខណៈខុសពីតំបន់ដទៃទៀតដោយសារកំពស់ទឹកភ្លៀងទាប ហើយដីមានប្រភេទដីដូចៗគ្នា។

១០៧. ប្រព័ន្ធមជ្ឈដ្ឋានហ៊្សែនរបស់តំបន់នេះអាចកំណត់បានតាមរយៈរបបទឹកភ្លៀងទាប (១៤០០-២០០០ម.ម) និងដីដែលមានប្រភេទដូចគ្នា។ ខុសពីប្រព័ន្ធមជ្ឈដ្ឋានហ៊្សែនតំបន់ពាយ័ព្យ ដែលភាគច្រើនគ្របដណ្តប់ទៅដោយដីជាដីជាតិ ដែលមានអាយុផ្សេងៗគ្នា។

១០៨. លក្ខណៈរបស់រុក្ខជាតិ និងសារព័ន្ធរបស់វា: ព្រៃពាក់កណ្តាលស្រោងនៅក្នុងតំបន់ទំនាបកណ្តាលភាគច្រើនគ្រប់ដណ្តប់ទៅដោយ *Irvingia, Mimosops, Pahudia, Pterocarpus, Shorea, Sindora and Vitex* (Legris & Blasco, 1972; Rollet 1972)។

## ៤-២-៤ លំនាំនៃការប្រើប្រាស់ដី

១០៩. ជាច្រើនជំនាន់មកហើយរាល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រទេសមួយផ្នែកធំ គឺផ្អែកលើកសិកម្ម ដែលបានប្រមូលផ្តុំនៅជុំវិញតំបន់ទំនាបទន្លេមេគង្គ។ ដំណាំកសិកម្មដែលមានគឺ : ស្រូវ កៅស៊ូ សណ្តែក កប្បាស ពោត អំពៅ ម្នាស់ និងបន្លែផ្សេងៗទៀត។ ប៉ុន្តែថ្មីៗនេះសង្កេតឃើញមានការរីកដុះដាលនូវចលនា នៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្មជាច្រើន ដែលជាទិសដៅរបស់ រដ្ឋាភិបាលនៅក្នុងការកាត់បន្ថយភាពក្រីក្រជនបទ តាមរយៈការទាក់ទាញវិនិយោគិនឱ្យធ្វើការវិនិយោគ នៅក្នុងវិស័យកសិកម្ម។

១១០. គួរឱ្យកត់សំគាល់ផងដែរថា ការផ្លាស់ប្តូរនូវលំនាំនៃការប្រើប្រាស់ដីនៅក្នុងប្រទេសយើង គឺកើតមាន ឡើងដោយសារហាយនភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ក្នុងរយៈពេលនៃបណ្តាឆ្នាំដែលសង្គ្រាមស៊ីវិល បានអូសបន្លាយកុំរ៉ែ ក្នុងនោះផ្ទៃដីមួយភាគធំត្រូវបានបោះបង់ចោល ហើយបន្ទាប់មកក៏ក្លាយទៅជាដីដែល គ្មានជីជាតិ។ គ្រោះមហន្តរាយដែលកើតមានឡើងកន្លងមកបានជំរុញឱ្យមានការផ្លាស់ប្តូរ ទីកន្លែងរស់នៅរបស់ ប្រជាជនជនបទឆ្ពោះទៅតំបន់ខ្ពង់រាប ដើម្បីរបកបរបរនិងផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគាត់។ ជាលទ្ធផល យន្តការនេះបាននាំមកនូវកំណើននៃសម្ពាធទៅលើធនធានធម្មជាតិ (ព្រៃឈើ) ហើយនិងរីកដាលបន្តិចម្តងៗ ឆ្ពោះ ទៅរកតំបន់ភ្នំដោយសារការធ្លាក់នូវធនធានព្រៃឈើនៅក្នុងតំបន់ទំនាប។

## ៤-៣ ការពិនិត្យនិងវាយតំលៃស្ថានភាពធនធានព្រៃឈើលើរូបភាពថតពីអាកាសដោយប្រើ Paramotor

១១១. តាមរយៈរូបភាព Photo Index Maps នៅលើចំណុចទាំង១០ (**ឧបសម្ព័ន្ធ៤-៥:** Photo Index A, B, C, D, E, F, G, H, I, J, ) បង្ហាញអោយឃើញថា គំរបព្រៃនិងធនធានព្រៃឈើមានលក្ខណៈជាព្រៃ ស្រោង ដែលទទួលរងការរំខានធ្ងន់ធ្ងរ ឬអាចយល់បានថាជាព្រៃពាក់កណ្តាលស្រោងរេចរិល ចំណែកឯដីដែល គ្មានព្រៃ គឺជាដីដែលប្រជាពលរដ្ឋក្នុងតំបន់ធ្វើការរានកាប់ឆ្ការដើម្បីដាំដំណាំ និងដីដែលក្រុមហ៊ុនទើបតែធ្វើការ ឈូសឆាយ ហើយកាលពីរដូវប្រាំងកន្លងទៅនេះ។ ព្រៃដែលមាននៅសេសសល់ក្នុងតំបន់នេះ ស្ទើរតែបាត់បង់តម្លៃ ពាណិជ្ជកម្មទាំងស្រុងហើយ។

១១២. ការសិក្សាទៅលើរូបភាពនេត្រាទស្សន៍-១ អំពីស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់ដីសម្បទាន បង្ហាញ ថា ព្រៃឈើទាំងនេះមានលក្ខណៈជាព្រៃចំរុះ ស្ថានភាពគំរបព្រៃមានលក្ខណៈបង្គួរ និងមានការរំខានពីការ កាប់រានធ្វើចំការរបស់ប្រជាជននៅរួចទៅហើយ។ ចំពោះរូបភាពនេត្រាទស្សន៍-២ សង្កេតឃើញ មានដីវាល ដែលបានកាប់ឈូសឆាយដោយក្រុមហ៊ុន ដើម្បីដាំដំណាំកៅស៊ូនៅក្នុងតំបន់នោះ ហើយក៏ឃើញមានសំណាក ចំការចាស់ផងដែរ (ជាចំការបុស្ស) របស់ប្រជាជនក្នុងមូលដ្ឋាន។ តាមការជួបសន្ទនាជាមួយនឹងអាជ្ញាធរ មូលដ្ឋាន និងប្រជាពលរដ្ឋក្នុងតំបន់នោះ បានអោយដឹងថា នៅក្នុងតំបន់ដូចបានរៀបរាប់ខាងលើនេះពិតជាមាន

ដីចំការចន្ទី និងដីស្រែចំការចាស់របស់ពួកគាត់មែន តែត្រូវបានក្រុមហ៊ុនដោះស្រាយឱ្យរួចហើយ តែនៅមានសេសសល់តិចតួចតាមមាត់អូរ ដែលក្រុមហ៊ុននឹងត្រូវដោះស្រាយបន្ត។

១១៣. តាមរយៈការសិក្សាអំពីស្ថានភាពប្រើប្រាស់នៅលើគន្លងហោះហើរចំងាយ ៣៨គម គ្របដណ្តប់លើផ្ទៃដីទំហំប្រមាណ ១៨៥៤ហិកតា សង្កេតឃើញមានការប្រើប្រាស់ដី (ចំការបុស្ស) របស់ប្រជាជននៅក្នុងឃុំពពក។ ជាក់ស្តែងតាមព័ត៌មានដែលទទួលបានពីក្រុមប្រឹក្សាឃុំពពក និងអភិបាលស្រុកស្នោង បានឱ្យដឹងថានៅតំបន់នេះពិតជាមានដីស្រែ-ចំការស្វាយចន្ទីរបស់អ្នកភូមិនៅទីនោះ។

## ៤-៤ លទ្ធផល និងការពិភាក្សា

### ៤-៤-១ រុក្ខអេកូឡូស៊ី

១១៤. បច្ចុប្បន្ននេះមិនទាន់មានការសិក្សាអំពីភាពសម្បូរណ៍បែប របស់រុក្ខជាតិបានច្បាស់លាស់នៅឡើយទេ។ តែទោះយ៉ាងនេះក្តី Dy Phon (2000) និងក្រសួងបរិស្ថាន (២០០២) បានបង្ហាញថា មានរុក្ខជាតិចំនួន២.៣០៨ប្រភេទ ក្នុងចំណោមរុក្ខជាតិសរុបចំនួន ៨.០០០ប្រភេទ ដែលមាននៅក្នុងគណ្ឋចិន *(Flore Générale de L'Indochine)* ស្ថិតក្នុង **genera** ចំនួន៨៥២ និង១៦៤អំបូរ។

១១៥. ការសិក្សាបង្ហាញថា នៅក្នុងប្រភេទព្រៃស្រោងរបស់តំបន់សម្បទាន មានរុក្ខជាតិចំនួន ៩៨ប្រភេទ (មានក្នុងតារាង៤-៦) ជុល្លិព្រឹក្ស៥៥ប្រភេទ(មានក្នុងតារាង៤-៧) និងតិណជាតិចំនួន៦៨ប្រភេទ(មានក្នុងតារាង៤-៨)ខាងក្រោម។ ភាពសម្បូរណ៍បែប និងសមាសភាពនៃរុក្ខជាតិ ទាំងនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងការពន្យល់បកស្រាយពី រចនាសម្ព័ន្ធទីជំរកដោយលោក Scweithelm and Chhay 2007 ដោយបាន និយាយថា នៅក្នុងព្រៃល្បោះ គ្របដណ្តប់ដោយប្រភេទរុក្ខជាតិ ដូចជា ខ្លុង ត្បែង ធ្នឹក រាំងភ្នំ នាងផ្អែក ក្នុងពេលដែលពពួកស្បូវ និងស្មៅព្រិច ជាពពួករុក្ខជាតិថ្នាក់ក្រោម។ ចំណែកឯនៅក្នុងព្រៃពាក់កណ្តាលស្រោងវិញសម្បូរណ៍ទៅដោយ *Lagerstroemia cochinchinesis, Xylia xylocarpa, Cratoxylum conchinchinense,* and *Shorea siamensis, Irivingia malayana* and that understory *Arundinaria pusilla* and *Bambusa bambos*។

១១៦. លោក Tran and Kol (1995) បានបញ្ជាក់ថា នៅក្នុងព្រៃស្រោងប្រភេទឈើដែលលុបគឺ *Dipterocarpus alatus, Polyalthia cerasoides,* and *Mangifera duperrean*។ ប៉ុន្តែការសិក្សាបង្ហាញថា ប្រភេទដែលលុបក្នុងតំបន់នេះគឺ *Lagerstroemia cochinchinesis, Polyalthia cerasoides, Amomum elephantrum,* and *Irvingia malayana,* and that understory species were *Korthalsia lacinosa* and *Nephelium hypoleucum*។

## តារាង៤-៦ ប្រភេទរុក្ខជាតិដែលមានដុះក្នុងព្រៃស្រោង

| No | Local Name | Known Uses | Class | BOTANICAL NAME |
|---|---|---|---|---|
| 1 | បាក់ដង |  | 5 | Gardennia sp |
| 2 | ពពាលខែ | ថ្នាំគ្រុនជាក់ | 5 | Terminalin Balatasteud |
| 3 | ពពូល |  | 2 | Vitex sp.,Verbenacees |
| 4 | ពពេល | ពាណិជ្ជកម្ម | 2 | Hopea recopei, Dipterocarpacees |
| 5 | បង្គៅ | ថ្នាំគ្រុនជាក់ | 4 | Aglaia gigantia, Meliacees |
| 6 | ពភ្លាប្រើស |  | 5 | Grewia paniculata |
| 7 | ពង្រ | ហូបផ្លែ | 5 |  |
| 8 | ដើមពួច |  | 5 |  |
| 9 | ចាន់ត្រមារ |  | 5 |  |
| 10 | ចង្គូរគ្នាត |  | 5 |  |
| 11 | ចំបក់ | ពាណិជ្ជកម្ម | 5 |  |
| 12 | ជន្លះ |  | 5 |  |
| 13 | ដង្គាបក្ដាម | ហូបផ្លែ | 5 | Antidesma ghaasembillia. |
| 14 | ដក់ព័រ |  | 5 | Markhamia pierrei. |
| 15 | ដូងចែម | ពាណិជ្ជកម្ម | 2 | Tarrietia javanica, Sterculiacees |
| 16 | ចែចរ |  | 5 |  |
| 17 | ជើងគោ |  | 5 |  |
| 18 | ចេកទុំ |  | 4 | Cinnamomum litsaefolium, Lauracees |
| 19 | ដើមប៉ា |  | 5 |  |
| 20 | ដើមឡង់ |  | 5 |  |
| 21 | ល្ងៀង | ពាណិជ្ជកម្ម | 4 | Cratoxylon orumifolium, Hypericacees |
| 22 | មៀនព្រៃ | ហូបផ្លែ | 5 |  |
| 23 | ភ្លៅនាង |  | 5 | Hemalium |
| 24 | ភ្លៅសំពោច | ធ្វើអុស | 5 |  |
| 25 | ផ្ដៀក | ពាណិជ្ជកម្ម | 3 | Anisoptera glabra, Dipterocarpacees |
| 26 | ភ្ញៀវ | ហូបផ្លែ | 5 |  |
| 27 | ផ្លែស្រែង | ថ្នាំផ្សះ | 5 |  |
| 28 | ឈើភ្លើង | ថ្នាំសសៃរ | 5 | Diospyros nitida |
| 29 | ឈើទាល | ពាណិជ្ជកម្ម | 3 | Dipterocarpus costus, Dipterocarpacess |

Draft

| | | | | |
|---|---|---|---|---|
| 30 | គ្រើល | ពាណិជ្ជកម្ម | 1 | Melanorrhea laccifera, Aanacerliacees |
| 31 | ស្មៀង | | 5 | |
| 32 | សិរមាន់ | ហូបផ្លែ | 5 | Neptcelium xerospermum |
| 33 | ខ្វាវ | | 3 | Adina cordipolea, Rubiscees |
| 34 | ធ្នូក | ពាណិជ្ជកម្ម | 4 | Parimarium annamensis, Rosacees |
| 35 | អាចមិសត្វ | | 5 | |
| 36 | អាឡោក | | 5 | |
| 37 | អំពិលព្រៃ | | 5 | |
| 38 | ញរព្រៃ | | 5 | Morinda |
| 39 | កង្ហារ | | 5 | |
| 40 | គគីរ | ពាណិជ្ជកម្ម | 2 | Hopea ferrea, Diptercarpacees |
| 41 | កំប៉ែត | | 5 | |
| 42 | កន្ទួតព្រៃ | | 5 | Phyllanthus emdilica. |
| 43 | កន្ទុយជូន | | 5 | |
| 44 | គុម្ពភ្លេង | | 5 | |
| 45 | ល្ហុសក្រហម | | 5 | |
| 46 | វលាយ | | 5 | Azadirachta. Indica |
| 47 | ម្ទូរក្រមួច | | 5 | |
| 48 | ម្កាក់ព្រៃ | | 5 | |
| 49 | រម៉ាំង | | 5 | |
| 50 | ភ្លូ | | 5 | |
| 51 | ភ្ញាស | | 5 | |
| 52 | ភ្លូង | បង្គោលរបង | 5 | Memecylon Laevigatum |
| 53 | រាំងភ្នំ | | 2 | Pentacme Siamensis, Dipterocarpacees |
| 54 | ព្រីង | អុសដុត សរសរផ្ទះ | 4 | Eugenia sp, Myrtacees |
| 55 | ព្រុស | បង្គោលរបង | 4 | Garcinia ferrea |
| 56 | ច្រម៉ាស់ | សរសរផ្ទះ | 3 | Vatica astrotricha, Diptericaroacees |
| 57 | រកា | | 5 | Bombax ceiba Bombaceae |
| 58 | ក្រាយ | ធ្យូង | 4 | Albizzia thorelli, Mimosees |
| 59 | ក្របៅ | | 4 | Hydnocarpus anthelmitica, Flacourtiacees |
| 60 | កកោះ | ពាណិជ្ជកម្ម | 2 | Sindora cochinchinensis, Caesalpinees |
| 61 | គ្រង់ | ហូបផ្លែ | 5 | Aporosa sp. |

Draft

| | | | | |
|---|---|---|---|---|
| 62 | ក្រញូង | ពាណិជ្ជកម្ម | 1 | Dalbergia cochinclinensis, Pepilionacees |
| 63 | ក្រឡាបួស | | 5 | |
| 64 | ក្រឡាញ់ | ពាណិជ្ជកម្ម | 2 | Dialium cochinchinensis, Caesalpinees |
| 65 | ក្រូចព្រៃ | | 5 | |
| 66 | រំដួល | ហូបផ្លែ | 5 | Popowia diospyrifolia |
| 67 | រំដេញ | | 5 | |
| 68 | ស្រឡៅ | ពាណិជ្ជកម្ម | 2 | Lagerstroemia sp, Lythracess |
| 69 | ស្រគំ | សរសរផ្ទះ | 3 | Payena elliptica, Sapotacees |
| 70 | ត្រាច | ពាណិជ្ជកម្ម | 3 | Dipterocarpus intricatus, Dipterocarpacess |
| 71 | ត្រប់ទុំ | ក្ដាបន្ទះ | 4 | Crypteronia pariculata, Lythracees |
| 72 | ត្របែកព្រៃ | | 5 | |
| 73 | ត្រមែង | ដុតធ្យូង | 4 | Carallia lucida, Rlhzophoracees |
| 74 | ត្រសេក | ពាណិជ្ជកម្ម | 2 | Peltophorum ferrugineum, Caesalpinees |
| 75 | ព្រហូត | ថ្នាំរាគមូល | 5 | |
| 76 | ត្រឡាត់ | | 3 | Vatica philastreava, Dipterocarpacees |
| 77 | ទ្រមូង | ធ្វើម្ហូរ | 4 | Garcinia schomburghiana-Guttiferes |
| 78 | ត្រយឹង | ថ្នាំត្រជាក់ | 5 | Diospyros gelferi, Ebenacees |
| 79 | ស្ពង់ | | 5 | Tetrameles mudiflora, Datiscacees |
| 80 | ស្មាច់ | ពាណិជ្ជកម្ម | 4 | Melaleuca leucadendron, Myrtacees |
| 81 | ស្មាក្របី | | 4 | Knema Corticosa |
| 82 | សង្កែ | | 5 | |
| 83 | សំប៉ារ | | 2 | Artocarpus sempervirens, Urticacees |
| 84 | សំបោរបាយ | | 5 | |
| 85 | ភ្លៅសំពោច | ចំណីរសត្វហូបផ្លែ | 5 | |
| 86 | សំរង់ | | 5 | Sterculia Lychnephora |
| 87 | ស្នួល | | 5 | Dalbergia rcigresens |
| 88 | ស្វាយព្រៃ | | 5 | Streblus asper |
| 89 | សុក្រំ | ពាណិជ្ជកម្ម | 2 | Xylia dolabriformis, Mismosees |
| 90 | ស្វាយព្រៃ | ពាណិជ្ជកម្ម | 4 | Mangfifera, indeca, Anacardiacess |
| 91 | ត្របត់ | | 5 | |
| 92 | ត្រយុត | | 5 | |
| 93 | ទំពូង | ថ្នាំសសៃរ | 5 | Mallotus Coehinchinensis |



Draft

| | | | | |
|---|---|---|---|---|
| 94 | ស្វាខ្មី | | 5 | |
| 95 | ខ្ចិត | | 5 | |
| 96 | ខ្ទុំ | | 5 | Mitragyna diversifolia, Havil Rubiaceae |
| 97 | ខាន់ស្លាក់ | | 5 | |
| 98 | យាមបោង | | 5 | |

តារាង៤-៧ ប្រភេទរុក្ខព្រឹក្សដែលជួបប្រទះតាមសងខាង Transect ចំងាយ ១០ម៉ែត្រ

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | សរុប | ការប្រើប្រាស់ |
|---|---|---|---|---|
| 1 | ឬស្សី | | ច្រើន | |
| 2 | ជើងចាប | | ច្រើន | |
| 3 | វល្លិល្មៀត | | ច្រើន | |
| 4 | ឥសីផ្សំស្រេច | | ជួបញឹកញាប់ | |
| 5 | ដើមទ្រៀល | | ជួបញឹកញាប់ | |
| 6 | ផ្តៅស្រែង | | ជួបញឹកញាប់ | |
| 7 | អន្ទេងព្រៃ | | ជួបញឹកញាប់ | |
| 8 | ដើមពូច | | ជួបញឹកញាប់ | |
| 9 | ពាន់ធ្លង | | ច្រើន | |
| 10 | រំពាត់ជ្រូក | | ច្រើន | |
| 11 | ចាក់សែង | | ច្រើន | |
| 12 | ដំឡូងទឹក | | ច្រើន | យកមើមហូប |
| 13 | ពោះមាន់ | | ច្រើន | ចងរបង វិញពួរ |
| 14 | ធ្មេញត្រី | | ច្រើន | |
| 15 | ស្លែង | | ច្រើន | |
| 16 | ផ្តៅកន្ទួង | | ជួបញឹកញាប់ | វិញពួរ |
| 17 | ផ្តៅឆ្នាំង | | ជួបញឹកញាប់ | វិញពួរ ចាកសង្រែក |
| 18 | ខ្លួត | | ច្រើន | |
| 19 | ធ្មុងកញ្ចុះ | | ច្រើន | |
| 20 | អំពិល | | ច្រើន | កាប់ដើមយកទឹកផឹក |
| 21 | ជង្គង់អណ្តើក | | ច្រើន | ហូបផ្លែ |
| 22 | ជន្ទល់ពងមាន់ | | ជួបញឹកញាប់ | |
| 23 | ដើមបែកផ្សែង | | ច្រើន | ថ្នាំថ្មោះ គ្រិច |
| 24 | ដើមអញ្ចាញ | | ច្រើន | ថ្នាំត្រជាក់ |

| | | | | |
|---|---|---|---|---|
| 25 | ដើមអំពិល | | ច្រើន | ម្ហូប |
| 26 | ម្ទូរល្មម | | ច្រើន | ធ្វើម្ហូប |
| 27 | ភ្នួស្បាត | | ច្រើន | ថ្នាំផ្សះ |
| 28 | ក្រសាំង | | ជួបញឹកញាប់ | ម្ហូប |
| 29 | បាយញ៉ៀញ | | ច្រើន | |
| 30 | វល្លិស្លែងពិណ | | ច្រើន | ចាក់ធ្វើកន្ទេល |
| 31 | វល្លិកញ្ចូញ | | ជួបញឹកញាប់ | ក្រងទ្រូ ស្នេហ៍មុខ |
| 32 | វល្លិក្លិនទា | | ជួបញឹកញាប់ | ថ្នាំគ្រុនចាញ់ |
| 33 | ពាន់ដែក | | ជួបញឹកញាប់ | |
| 34 | ជន្ទល់មេឃ | | ច្រើន | |
| 35 | ដំឡូងទាន | | ច្រើន | យកមើមហូប |
| 36 | ដោះក្របី | | ច្រើន | |
| 37 | កញ្ជាស់ | | ច្រើន | |
| 38 | ល្អាក់ទឹក | | ច្រើន | |
| 39 | រមូលភ្លើង | | ច្រើន | |
| 40 | ទ្រមូងខ្មោះ | | ច្រើន | ក្របលប ទ្រូ ព្រួល |
| 41 | ខ្នាយមាន់ | | ជួបញឹកញាប់ | |
| 42 | ទាលក្រាញ់ | | ជួបញឹកញាប់ | ថ្នាំសត្វ |
| 43 | បាយក្តាំង | | ជួបញឹកញាប់ | |
| 44 | អង្គរសិល្ប៍ | | ច្រើន | |
| 45 | ក្របាស់ព្រៃ | | ជួបញឹកញាប់ | ថ្នាំស្បូន |
| 46 | កន្ទេចអាល | | ច្រើន | |
| 47 | រំពាត់សេះ | | ច្រើន | |
| 48 | ជើងគោស្បាត | | ច្រើន | ថ្នាំស្បូន |
| 49 | ដីវប្រាំងក | | ច្រើន | ថ្នាំរោគស្ត្រី |
| 50 | វង្សព្រះអាទិត្យ | | ជួបញឹកញាប់ | |
| 51 | ត្រដិត | | ជួបញឹកញាប់ | |
| 52 | ម្រេចទន្សាយ | | ច្រើន | ថ្នាំស្បូន |
| 53 | អង្រែដែក | | ច្រើន | ថ្នាំកូនខ្ចី ជំនួយកំលាំង |
| 54 | ត្បាល់ដែក | | ច្រើន | ថ្នាំប៉ូវក្រលាន |
| 55 | រំដេញមាស | | ច្រើន | ថ្នាំសរសៃ |



Draft

## តារាង៤-៨ ប្រភេទ ទិណជាតិដែលបានជួបប្រទះតាមសងខាងផ្លូវ

| ប្រភេទទិណជាតិដែលជួបប្រទះតាមសងខាង Transect ចំងាយ១០ម៉ែត្រ | | | | |
|---|---|---|---|---|
| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | សរុប | ការប្រើប្រាស់ |
| 1 | ដើមដង្កោ | | ច្រើន | |
| 2 | ដើមផ្កាវ | | ច្រើន | |
| 3 | ប្រទាល | | ច្រើន | |
| 4 | បណ្តូលពេជ្រ | | ច្រើន | |
| 5 | ជុជ | | ច្រើន | |
| 6 | ជុយ | | ច្រើន | |
| 7 | ជីស | | ច្រើន | |
| 8 | ពោះវៀនមាន់ | | ច្រើន | |
| 9 | ដោះគង់ | | ច្រើន | |
| 10 | ផ្តៅ | | ច្រើន | |
| 11 | ជោម | | ច្រើន | |
| 12 | ត្រៀល | | ច្រើន | |
| 13 | ស្លែង | | ច្រើន | |
| 14 | សៅម៉ៅ | | ជួបញឹកញាប់ | |
| 15 | ខ្លែងពណិ | | ច្រើន | |
| 16 | អានោ | | ច្រើន | |
| 17 | អង្គញ | | ច្រើន | |
| 18 | អន្ទង | | ច្រើន | |
| 19 | កណ្តាប់ចង្កេរ | | ច្រើន | |
| 20 | គុយ | | ច្រើន | |
| 21 | ក្របីក្រោស | | ច្រើន | |
| 22 | ក្រវ៉ាន់ | | ច្រើន | |
| 23 | ត្រឡំពេន | | ច្រើន | |
| 24 | តាលេនពេន | | ច្រើន | |
| 25 | ទន្និញក្រហម | | ច្រើន | |
| 26 | ទន្និញស | | ច្រើន | |
| 27 | ទឹកដោះ | | ច្រើន | |
| 28 | យាវ | | ច្រើន | |
| 29 | ពន្លៃព្រៃ | | ច្រើន | |
| 30 | បូមក្តាម | | ច្រើន | |

Draft

| | | | | |
|---|---|---|---|---|
| 31 | ស្មៅបាយក្តាំង | | ច្រើន | ចំណីសត្វ |
| 32 | ស្មៅបែកក្បាល | | ច្រើន | ចំណីសត្វ |
| 33 | ស្មៅម្តេងព្រៃ | | ច្រើន | ហូប |
| 34 | ស្មៅស្លែថ្ម | | ច្រើន | |
| 35 | ស្មៅកន្ទុយកេ | | ជួបញឹកញាប់ | |
| 36 | ស្មៅអន្ទេន | | ច្រើន | ចំណីសត្វ |
| 37 | ស្មៅប្រក់អណ្តើក | | ច្រើន | |
| 38 | ស្មៅប្រទាលជន់ព្រៃ | | ច្រើន | |
| 39 | ស្មៅត្រសិត | | ច្រើន | |
| 40 | ស្មៅស្បូវបាយ | | ច្រើន | ប្រក់ផ្ទះ |
| 41 | ស្មៅស្បូវអណ្តាស | | ច្រើន | |
| 42 | ស្មៅស្បូវកន្ទង | | ច្រើន | ប្រក់ផ្ទះ |
| 43 | ស្មៅស្បូវឃ្លាំង | | ច្រើន | ប្រក់ដំបូលផ្ទះ |
| 44 | ស្លែដី | | ច្រើន | |
| 45 | ថ្នក់ទឹក | | ច្រើន | |
| 46 | កណ្តាលបាត | | ច្រើន | |
| 47 | ផ្សិតក្ងោក | | ច្រើន | |
| 48 | ផ្កាអកគីដេ | | ជួបញឹកញាប់ | |
| 49 | ផ្សិតចំបក់ | | ច្រើន | ចំណីសត្វ |
| 50 | ផ្សិតដី | | ច្រើន | |
| 51 | ផ្សិតភ្លើង | | ច្រើន | យកហូប |
| 52 | ផ្សិតឈើ | | ច្រើន | |
| 53 | ផ្សិតកញ្ជេរ | | ច្រើន | |
| 54 | ផ្សិតផ្ទួកផ្ករ | | ច្រើន | ចំណីសត្វ |
| 55 | ផ្សិតត្រចៀកកណ្តុរ | | ច្រើន | យកហូប |
| 56 | ប្រទាលជាន់ព្រៃ | | ជួបញឹកញាប់ | |
| 57 | ត្បាល់ដែក | | ជួបញឹកញាប់ | |
| 58 | ផ្តៅល្វីង | | ច្រើន | វិញពួរ ឬ ខ្សែ |
| 59 | ផ្តៅកន្ទះ | | ច្រើន | វិញពួរ ឬ ខ្សែ |
| 60 | ផ្តៅឆាំង | | ជួបញឹកញាប់ | វិញពួរ ឬ ខ្សែ |
| 61 | ផ្តៅសន្ទូច | | ជួបញឹកញាប់ | |
| 62 | ចង្កេះអង្រ្កង | | ជួបញឹកញាប់ | ជំងឺទាសរីងរៃ |

Draft

| | | | | |
|---|---|---|---|---|
| 63 | ដើមក្រេះ | | ច្រើន | បន្សាបពុលអាហារ |
| 64 | ដើមរលាយឈាម | | ច្រើន | ថ្នាំគ្រាំ ជំនួយសរសៃ |
| 65 | គោមួយ | | ជួបញឹកញាប់ | ផ្សះស្បូន ជំនួយសរសៃ ជំនួយកំលាំង |
| 66 | ស្រោមដាវ | | ច្រើន | ថ្នាំស្បូន |
| 67 | ទេពពង្រូល | | ច្រើន | ថ្នាំស្បូន និង ផ្សះ |
| 68 | ព្រះកំចាត់ | | ជួបញឹកញាប់ | ថ្នាំអារើស |

## ៤-៤-២ សត្វអេកូឡូស៊ី

**១១៧.** ការតាមរយៈការដើរលើគន្លងឆ្លងកាត់ (Mega Transect Walk) ចំងាយ២០,៣គ.ម ក្រុមការងារបានកត់ត្រានូវពពួកសកុណជាតិចំនួន៣៧ (តារាង៤-៩ប្រភេទសកុណជាតិដែលមាននៅក្នុងតំបន់សម្បទាន)។ ក្នុងចំណោមសកុណជាតិទាំងអស់នេះ Alexandrine Parakeet *Psittacula alexandri*, Siamese Fireback *Lophura diardi*, and Chestnut-headed Partridge *Arborophilia cambodiana* ត្រូវបានចាត់ទុកថាជាប្រភេទដែលកម្រនៅក្នុងប្រទេសយើង។

**តារាង ៤-៩ : ចំនួនសត្វព្រៃ (សត្វស្លាប) ដែលបានអង្កេតនៅក្នុងតំបន់របស់ក្រុមហ៊ុន**

| Khmer name | English name | Scientific name | # of records |
|---|---|---|---|
| ទាវខៀវ | Indian Roller | *Coracias benghalensis* | 6 |
| ត្រដេវតូច | Green Bee-eater | *Merops orientalis* | 5 |
| សេកក្រិច | Vernal Hanging Parrot | *Loriculus vernalis* | 10 |
| សេកអាត់ | Blossom-headed Parakeet | *Psittacula roseata* | 24 |
| ពពូលជើងលឿង | Treron Phocnicoptera | - | 11 |
| ពញ្លាក់ | Indian Nightjar | *Caprimulgus asiaticus* | 1 |
| មាម | Glavcidium Brodiei | - | 3 |
| ត្រដេវវិចទូល | Red-wattled Lapwing | *Vanellus indicus* | 2 |
| កុកក្រក | Chinese Pond Heron | *Ardeola bacchus* | 1 |
| អន្ទេបខ្មៅ | Black Drongo | *Dicrurus macrocercus* | 2 |
| អន្ទេបកន្ទុយកន្ត្រៃ | Greater Racket-tailed Drongo | *Dicrurus paradiseus* | 1 |
| ល្វាចេក | Oriental Magpie Robin | *Copsychus saularis* | 1 |
| កព្រៀច | Vinous-breasted Starling | *Sturnus burmannicus* | 2 |
| ពពិចក្បាលខ្មៅចុងខ្នងស | Sooty-headed Bulbul | *Pycnonotus aurigaster* | 15 |
| មាន់ព្រៃ | Red Junglefowl | *Gallus gallus* | 2 |
| ក្រួចអ៊ុត | Barred Buttonquail | *Turnix suscitator* | 5 |
| ត្រសេះតូច | Common Flameback | *Dinopium javanense* | 2 |

| | | | |
|---|---|---|---|
| បាគូ | Common Hoopoe | *Upupa epops* | 3 |
| ជចាត | Common Kingfisher | *Alcedo atthis* | 2 |
| ខ្លែងខ្មៅ | Black Kite | *Milvus migrant* | 1 |
| ញាំង | Wreathed Hornbill | *Aceros undulates* | 1 |
| សារិកាកែវក្របី | White-vented Myna | *Acridotheres javanicus* | 2 |
| ត្រលឹងត្រលង | Black-collared Straling | *Sturnus nigricollis* | 1 |
| ចាបក្រច | Yellow-vented Bulbul | *Pycnonotus goiavier* | 1 |
| ក្រួចសំពៅ | Chestnut-headed Partridge | *Arborophilia cambodiana* | 3 |
| ទទា | Chinese Francolin | *Francolinun pintadeanus* | 1 |
| ចេកខ្ចីស្លាបខៀវ | Blue-winged Leafbird | *Chloropsis cochinchinensis* | 2 |
| ចែកខ្ចី | Golden-fronted Leafbird | *Chloropsis aurifrons* | 1 |
| ចេកទេសតូច | Small Minivet | *Pericrocotus cinnamomeus* | 4 |
| លលកបាយ | Spotted Dove | *Streptopelia chinensis* | 2 |
| ចេកទុំខៀវ | Asian Brown Flycatcher | *Muscicapa dauurica* | 3 |
| ចាបដង្កូវ | Prinia | *Prinia spp* | 21 |
| ចាបដូនតា | Warbler | *Locustella spp* | 14 |
| ចាបកន្ទង់ | Olive-blacked Sunbird | *Nectarinia jugularis* | 1 |
| ជកវៃក | White-crested Laughinhthrush | *Garrulax leucolophus* | 4 |
| ជាបតេត | Common Tailorbird | *Orthotomus sutorius* | 3 |
| គូត | Burceros Bicornis | - | 5 |
| *Number of species* | | | *37* |
| *Number of individuals* | | | *168* |

១១៨. ការសិក្សាបង្ហាញថា បក្សីដែលសម្បូរណ៍ជាងគេនៅក្នុងតំបន់សម្បទាននេះគឺ Sooty-headed Bulbul *Pycnonotus aurigaster*, Spotted Dove *Streptopelia chinensis,* White-crested Laughinhthrush *Garrulax leucolophus*, Prinia *Prinia spp*, Warbler *Locustella spp*, and Indian Roller *Coracias benghalensis* ដូចការអះអាងរបស់លោក *Joe and Other 2001* ដែលថា បក្សីទាំងនេះមានចំនួនច្រើនលើសលុបនៅតំបន់ខាងត្បូងជ្រោយឥណ្ឌូចិន ។

១១៩. លោក Tan and Poole, 2003 បានបញ្ជាក់ថា Blossom-headed Parakeet *Psittacula roseata*, Red-breasted Parakeet *Psittacula alexandri*, Red Junglefowl *Gallus gallus*, and Chinese Francolin *Francolinun pintadeanus* ដូចទៅនឹងរបាយការណ៍របស់រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សអន្តរជាតិនៅឆ្នាំ ២០០៧ ថាប្រភេទបក្សីទាំងអស់នេះជាប្រភេទលប់ នៅក្នុងប្រទេសកម្ពុជា ហើយភាគច្រើនជាប្រភេទដែលរស់នៅលើចុងឈើ (Barney et al, 2000) ។

១២០. បក្សីភាគច្រើនដែលជួបប្រទះនៅក្នុងតំបន់សម្បទានគឺ បក្សីដែលរស់លើចុងឈើ និងស៊ីចំណីលើដី។ ដោយឡែកបក្សីទឹក Waterbirds Common Kingfisher *Alcedo atthis,* Chinese Pond Heron *Ardeola bacchus*, Black-capped Kingfisher *Halcyon pileata*, White-breasted Waterhen *Amaurrmis phoenicrus*, and Intermediate Egret *Egretta intermedia* ក៏មានច្រើនដែរ ដោយសារតែមជ្ឈដ្ឋានរស់នៅមានអំណោយផល។ តែចំពោះ Prinia, Warbler, Chinese Francolin, Partridge, and Junglefowl ជាប្រភេទដែលរស់នៅ Understory ដូច្នេះហើយទើបសង្កេតឃើញថា បក្សីទាំងនេះមានលក្ខណៈប្លែកគ្នាខ្លាំងទៅតាមលក្ខណៈនៃមជ្ឈដ្ឋាននិមួយៗ (Masphal et al, 2009) ។

១២១. ការសិក្សាបង្ហាញថា មានថនិកសត្វចំនួន ០៦ប្រភេទ (តារាង៤-១០ ប្រភេទថនិកសត្វដែលជួបប្រទះនៅក្នុងតំបន់សម្បទាន ក្នុងចំណោមថនិកសត្វទាំងអស់នេះ ខ្លាឃ្មុំ ប្រើស និងទោចថ្គាល់លឿងត្រូវបានចាត់ទុកថាជាប្រភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់ (សេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០០៧) ។ ដោយឡែក Sambar deer *Cervus unicolor*, Lesser Oriental Chevrontian *Tragulus javanicus*, Fishing cat *Prionailurus viverrinus*, Pig-tailed Macaque *Macaca leonine*, Wild pig *Sus scrofa*, Red muntjac *Muntiacus muntjak*, and Civet *Viverra spp* were categorized ត្រូវបានចាត់ទុកថាជាប្រភេទដែលសម្បូរណ៍នៅក្នុងប្រទេសយើង ។

តារាង៤ -១០: ចំនួនសត្វព្រៃ (ថនិកសត្វ) ដែលបានអង្កេតនៅក្នុងតំបន់របស់ក្រុមហ៊ុន

| ប្រភេទថនិកសត្វដែលជួបប្រទះតាមសងខាង Transect ចំងាយ១០ម៉ែត្រ | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | រាប់តាមលំដាប់នៃ | | | | សរុប |
| | | | ការមើលឃើញ | ដានជើង | សំរែក | លាមក | |
| 1 | ក្តាន់ញែង | Tragulus Napu | 6 | 4 | 1 | 0 | 11 |
| 2 | ឈ្លូស | Muntiacus Muntjak | | 12 | 0 | 0 | 12 |
| 3 | ជ្រូកព្រៃ | Suss Scrota | | 19 | 0 | 2 | 21 |
| 4 | ស្កាធំ | Herpestes Urva | 1 | 0 | 0 | 0 | 1 |
| 5 | សំពោចធំ | Vivrra Megaspila | 6 | 0 | 0 | 0 | 6 |
| 6 | ខ្លាត្រី | Prionilurus Viverrinus | 1 | 0 | 0 | 0 | 1 |
| Grand total | | | 14 | 35 | 1 | 2 | 52 |

១២២. តារាង៤-១១ ខាងក្រោមបានបង្ហាញឱ្យឃើញថា ភាពសំបូរបែបនៃសត្វស្លាបដែលបានកត់ត្រានៅក្នុងតំបន់សិក្សាស្រាវជ្រាវ គឺមានចំនួនស្មើនឹង ៦៤ភាគរយ នៃលទ្ធផលដែលទទួលបានពីការសំភាសន៍ជាមួយប្រជាជនមូលដ្ឋាន រស់ក្បែរតំបន់ស្រាវជ្រាវ និងត្រូវជា ០៦ភាគរយ នៃចំនួនសត្វស្លាបសរុបក្នុងប្រទេសកម្ពុជា។

Draft

**១២៣.** មានថនិកសត្វចំនួន ០៦ប្រភេទត្រូវបានកត់ត្រា (**ក្នុងតារាង៤-១០ ចំនួនសត្វព្រៃ (ថនិកសត្វ) ដែលបានអង្កេតនៅក្នុងតំបន់របស់ក្រុមហ៊ុន**)។ ក្នុងចំណោមពពួកថនិកសត្វទាំងអស់នេះមានឈ្លូស និងជ្រូកព្រៃ ត្រូវបានចាត់ថាជាប្រភេទមានដោយបង្គួរ (MAFF,2007)។ តារាងលេខដដែលនេះ ក៏បានបង្ហាញអោយឃើញផងដែរថា ថនិកសត្វដែលកត់ត្រាបានមានចំនួនប្រមាណ២៨,៥៧ភាគរយ នៃចំនួនសត្វដែលបានពីការសំភាសន៍ប្រជាជនមូលដ្ឋាន ហើយត្រូវជា២,៧៥ភាគរយ នៃចំនួនថនិកសត្វសរុបនៅក្នុងប្រទេសកម្ពុជា។

**តារាង៤-១១: ការប្រៀបធៀបពីភាពសំបូរបែបរបស់សត្វស្លាប និងថនិកសត្វនៅក្នុងតំបន់សិក្សាស្រាវជ្រាវ ទៅនឹងលទ្ធផលពីការសំភាសន៍តំបន់ព្រៃការពារសេនេទិកស្រែពក និងទូទាំងប្រទេស**

| ប្រភេទ | តំបន់សិក្សាស្រាវជ្រាវ | ពីការសំភាសន៍ | ទូទាំងប្រទេស |
|---|---|---|---|
| សត្វស្លាប | ៣៧ | ៥៨ | ៦៣០ |
| ថនិកសត្វ | ០៦ | ២១ | ២១៨ |

*ប្រភព: ម៉ែន សូរិយាន់ និងអ្នកដទៃទៀត ២០០២, Jenny and Frank 2000*

### ៤-៤-៣ អំពីមច្ឆាជាតិ

**១២៤.** នៅក្នុងតំបន់សម្បទាននេះមិនសំបូរប្រភពទឹកស្រទាប់លើទេ ក្រៅពីអូរតូចៗពីរគឺ អូរដូងត្រាច និង អូរកោសលង់ មានតែត្រពាំងចំនួន០៥ដែលរីងនៅចុងរដូវប្រាំង។ តាមការសាកសួរពីប្រជាជនមូលដ្ឋាន បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុងតំបន់នោះ។ ប្រភេទត្រីសំខាន់ៗ ដែលពួកគាត់ធ្លាប់នេសាទមានដូចជា: **(១) ត្រីស:** ត្រីឆ្ពិន *(Barbonymus gonionotus)*, ត្រីស្រកាក្តាម (*Cyclocheilichthys apogon*), ត្រីចង្វាជញ្ជក់ដៃ (*Crossocheilus reticulatus*), ត្រីក្រោស (*Crossocheilus atrilimes*), ត្រីចង្វារនោង (*Garra fasciacauda*), ត្រីខ្នាន់ (*Hampala macrolepidota*), ត្រីអាចម៍កុក (*Labiobarbus siamensis*), **និង (២) ត្រីខ្មៅ:** ត្រីរស់ (*Channa Striata*), ត្រីកញ្ជនជ័យ (*Channa licius*) ត្រីឆ្លាំង *(Hemibagrus spilopterus)*, ត្រីកន្ធ្រប់ *(Catopa)* ត្រីកញ្ចុះ (*Mystus albolineatus*), ត្រីកញ្ចុះ (*Pseudomystus siamensis*) ត្រីកញ្ចុះ (*Mystus atrifasciatus*), ត្រីអណ្តែងងាំង (*Clarias nieuhofii*)។

## ៤-៥ ធនធានសង្គម និងសេដ្ឋកិច្ច

**១២៤.** លទ្ធផលនៃការធ្វើ PRA (ទំព័រ១២១-១៣០) កំណត់ហេតុ និងរបាយការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ ជាមួយថ្នាក់ដឹកនាំខេត្តស្រុក មន្ទីរ និងសហគមន៍ពាក់ព័ន្ធ លើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។



Draft

## ៤-៦ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

**១២៥.** ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវជាតិភាគច្រើនគឺជនបទ។ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងតំបន់នេះមានលក្ខណៈខុស១គ្នាទៅតាមទីប្រជុំជន ខេត្ត ស្រុក និងជនបទ។ ប្រជាជននៅក្នុងឃុំពពក ជាពិសេសប្រជាពលរដ្ឋក្នុង(ភូមិសំបូរ ភូមិ ត្រពាំងឬស្សី ភូមិកោះសំរោង និងភូមិពពក) ស្ទើរតែទាំងអស់រស់នៅក្នុងតំបន់ស្នូល និងតំបន់រណបនៃដីសម្បទានសេដ្ឋកិច្ច ដែលក្រុមហ៊ុនស្នើសុំ។ ក្រៅពីការប្រកបរបរធ្វើចំការ-ស្រែ ការរុករកផល-អនុផលព្រៃឈើ កាប់ឈើលក់ និងដាក់អន្ទាក់សត្វ ក្រោយពីប្រមូលផលស្រូវរួចមានគ្រួសារខ្លះ ពួកគាត់ទៅរកកាប់ឈើអុស និងឈើសំណង់ផ្សេង១លក់ឱ្យទៅឈ្មួញកណ្តាលដែលកមទិញដល់កន្លែងឬខ្លះទៀតឌុបទៅលក់ដល់ទីរួមស្រុកស្ទោងតែម្តង ក្រៅពីប្រជាជនដែលរស់ក្នុងតំបន់ស្នូល ពួកគាត់ប្រកបរបរលក់ដូរបន្តិចបន្តួចតាមដងផ្លូវលំគ្រួសក្រហមក្នុងឃុំពពក សម្រាប់បំរើតម្រូវការក្នុងភូមិ ឃុំនិងអ្នកដំណើរ។ មានគ្រួសារខ្លះទៀតដាំដំណាំ និងបន្លែបង្ការបន្តិចបន្តួចក្បែរ១ផ្ទះ (ក្បែរមាត់អណ្តូង និងអូរនានាសម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារ និងដោះដូរជាមួយអ្នកភូមិផងរបងជាមួយ។

**១២៦.** តាមរយៈការចុះសិក្សាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅទីនោះបង្ហាញថា ផលិតផលចំការស្វាយចន្ទីជាប្រភពចំណូលសំខាន់របស់គ្រួសារនីមួយ១។ តែផ្ទៃដីសំរាប់ធ្វើស្រែមានតិចតួច មិនអាចផ្តល់ឱ្យគ្រប់គ្រួសារឡើយ គ្រួសារដែលគ្មានដីស្រែបានទៅរានដីធ្វើចំការទៅតាមលទ្ធភាពរៀង១ខ្លួន។ គ្រួសារភាគច្រើនដាំស្វាយចន្ទី ទិន្នផលនៃមុខដំណាំនេះអាចធ្វើឱ្យប្រជាជននៅក្នុងតំបន់នេះមានជីវភាពធូរធារមួយកំរិត ក្នុងរយៈពេលពីឆ្នាំមុននេះ(២០០៩) ដែលតំលៃក្នុង១គីឡូក្រាមលក់បានក្នុងតំលៃ ២៥០០-៣០០០រៀល។ ក្រៅពីនោះពួកគាត់ប្រកបរបរកាប់អុស និងកាប់ឈើនៅក្នុងតំបន់អភិរក្ស។ ចំណូលដែលបានមកពីការធ្វើចំការ និងចំការស្វាយចន្ទីនេះក៏នៅតែមិនអាចទ្រទ្រង់នូវជីវភាពក្នុងគ្រួសាររបស់ពួកគាត់ល្អទេ ព្រោះគ្រួសារភាគច្រើនមានសមាជិកច្រើន ហើយការដាំដំណាំចន្ទីរបស់ពួកគាត់មាន លក្ខណៈជាយថាផល ចំណែកឯទិន្នផលស្រូវដែលទទួលបាននៅមានកំរិតទាបនៅឡើយគិតជាមធ្យមគឺ១-១,៥ តោន ក្នុង១ឆ្នាំមួយហិកតា ចំពោះស្វាយចន្ទីមាន ៥០០-៧០០ដើម/ហិកតា) ដូចនេះមួយឆ្នាំអាចទទួលបានប្រមាណ ២.៥០០.០០០-៣.១៥០.០០០រៀល (តាមការសាកសួរជាមួយ លោក ជាង គឿ ក្រុមប្រឹក្សាឃុំពពក) ។

**១២៧.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេង១គ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយ១។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រនៅក្នុងខេត្តកំពង់ធំមាន៖ ២៩.១០ភាគរយ (១៥៨.៩០៣ាន់) លើចំនួនប្រជាជនសរុប ៦២៤.៨៤៦នាក់ ក្នុងនោះមាន ៦២១.៨៣៣នាក់ ឬស្មើនឹង៩៩ភាគរយរស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀង

Draft

អង្គការសហប្រជាជាតិឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤)។ ជាទូទៅពួកគាត់បានចូលសាលាជាមធ្យមត្រឹមតែកំរិតថ្នាក់ទីប្រាំតែប៉ុណ្ណោះ។

១២៨. គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈមាន : គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងសហគន៍ដាច់ស្រយាលទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា។ ការសិក្សាបានបង្ហាញឱ្យឃើញថា អ្នកភូមិដែលរស់នៅតាមដងផ្លូវក៏ដូចជាប្រជាជនដែលរស់នៅតាមភូមិក្នុងឃុំពពកដែរ ពុំបានទទួលការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋានទេ។ មានគ្រួសារតិចតួចណាស់ដែលប្រើអាគុយខណៈដែលមួយចំនួនធំបានប្រើប្រាស់ចង្កៀងប្រេងសំរាប់បំភ្លឺនៅពេលយប់។ រីឯប្រភពថាមពលសំខាន់សំរាប់ការចំអិនអាហាររបស់ពួកគាត់គឺអុស ដែលអាចរកបានពីព្រៃដែលនៅមិនឆ្ងាយពីលំនៅដ្ឋានរបស់ពួកគាត់។

១២៩. ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើនគឺប្រើប្រាស់ផ្លូវជាតិលេខ៦ (ភ្នំពេញ-កំពង់ធំ) និង(កំពង់ធំ-ស្ទោង)រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅនឹងសហគមន៍ពួកគាត់ ជាផ្លូវលំក្រាលគ្រួសក្រហមដែលជាអំណោយរបស់ឯកឧត្តម ងួន ញ៉ិល ហើយផ្លូវមួយចំនួនទៀតជាផ្លូវរទេះ ឬផ្លូវលំដើរដោយជើង។ ផ្លូវទាំងនេះនៅក្នុងរដូវវស្សាមានសភាពរអិលពិបាកធ្វើដំណើរ តែមានភាពងាយស្រួលជាង២-៣ឆ្នាំមុន។ ដោយសារតែការធ្វើដំណើរចេញចូលមានលក្ខណៈល្អប្រសើរ ដូច្នេះហើយទើបធ្វើឱ្យការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងនេះជាមួយនឹងតំបន់ខាងក្រៅមានលក្ខណៈទូលំទូលាយ និងទទួលបានការយកចិត្តទុកដាក់តិចតួចពីបណ្តាភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ ដែលក្នុងនោះមានការផ្គត់ផ្គង់ទឹកស្អាត និងសាលារៀន ជាដើម ។

១៣០. ចំណែកឯការធ្វើដំណើរពីផ្លូវជាតិទៅកាន់ឃុំ និងភូមិនានានៅក្នុងស្រុកស្ទោង មានលក្ខណៈល្អប្រសើរជាងមុនដោយបានក្រសួងអភិវឌ្ឍន៍ជនបទ ជួសជុល និងថែទាំជាប្រចាំ ដោយឡែកផ្លូវពីស្រុកទៅកាន់ឃុំពពកនិងភូមិនានាមានលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ ដោយសារមានផ្លូវដែលជាអំណោយរបស់ឯកឧត្តម ងួន ញ៉ិល ដូច្នេះហើយទើបធ្វើឱ្យការប្រាស្រ័យ ទាក់ទងរវាងសហគមន៍ទាំងនេះជាមួយនឹងតំបន់ខាងក្រៅមានលក្ខណៈទូលំទូលាយ។

១៣១. លទ្ធផលនៃការសិក្សាអង្កេតបានបង្ហាញថា ក្នុងឃុំពពកងមានអនុវិទ្យាល័យមួយខ្នង មាន៣បន្ទប់ និងមានសាលាបឋមសិក្សា៣ខ្នងមាន១៤បន្ទប់មានគ្រូថ្នាក់អនុវិទ្យាល័យចំនួន៥នាក់ និងគ្រូបង្រៀនថ្នាក់បឋមសិក្សា ចំនួន១០នាក់។

## ៤-៧ ធនធានសង្គម និងវប្បធម៌

១៣២. ក្រុមការងារធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងភូមិសាស្ត្រ ដែលក្រុមហ៊ុន **ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ** បានស្នើសុំមានទីតាំងស្ថិតក្នុងឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ។

**ឃុំពពក** មានភូមិចំនួន៨គឺ: (១) ភូមិសំបូរ មាន១៨១គ្រួសារ (៩១៥នាក់) ស្រី ៤៩៩នាក់ (២)ភូមិអន្លង់ក្រាញ់មាន ៣៣៩ គ្រួសារ (១៩១២នាក់) ស្រី ៩៦៩នាក់ (៣) ភូមិកោះសំរោង មាន៤០គ្រួសារ (២៣៤នាក់) ស្រី ១៣១នាក់ (៤) ភូមិស្រែក្រសាំងមាន ២៤៦គ្រួសារ (១៧៨០២នាក់) ស្រី ៨៧១នាក់ (៥) ភូមិពែង ១០៩គ្រួសារ (៥៩២នាក់) ស្រី ២៨២នាក់ (៦) ភូមិខ្ទមមន មាន ៣២១គ្រួសារ (៥៩២នាក់) ស្រី ២៨២នាក់ (៧) ភូមិផ្ទះដើម មាន ៧០គ្រួសារ (៤១៤នាក់) ស្រី ២២៥នាក់ (៨) ភូមិ ត្រពាំងឫស្សី មាន ១២០គ្រួសារ (៨៩២នាក់) ស្រី ៦០២នាក់ ដូចនេះប្រជាជនសរុបទូទាំងឃុំមានចំនួន ៨៥៤៩នាក់ ក្នុងនោះមាន ស្រី ៤៦០៦នាក់ (តារាងស្ថិតិប្រជាពលរដ្ឋឃុំពពក ឆ្នាំ២០១០)។ ចំពោះភូមិដែលពាក់ព័ន្ធដីសម្បទានសេដ្ឋកិច្ចដែលក្រុមហ៊ុន **ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ** ស្នើសុំ គឺមាន៣ភូមិគឺ ភូមិសំបូរ និងភូមិពពក និងភូមិកោះសំរោង តែក្រុមហ៊ុនបានធ្វើការដោះស្រាយដីពាក់ព័ន្ធរួចស្រេចអស់ហើយ (តាមការផ្តល់ពត៌មានពីក្រុមប្រឹក្សាឃុំក៏ដូចជាប្រជាពលរដ្ឋក្នុងពេលប្រជុំ ពិគ្រោះយោបល់)។

**១៣៣.** លំនាំនៃការតាំងទីលំនៅនៅជនបទមានលក្ខណៈ ជាការតាំងទីលំនៅតាមសងខាងនៃបណ្តោយផ្លូវលំមានលក្ខណៈរកេតរកូត និងឃ្លាតពីគ្នាដោយអន្លើៗ និងតាមផ្លូវលំចូលទៅក្នុងភូមិខ្លះមានលក្ខណៈប្រមូលផ្តុំ និងមានការតាំងលំនៅអមសងខាងផ្លូវលំ។

Draft